ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥/ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១/ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រមក/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់ អំពីការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដែលហៅកាត់ថា "កម្មវិធី"។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសាលារៀនសាធារណៈដែលត្រូវបានជ្រើសរើសឱ្យអនុវត្តកម្មវិធី។

**មាត្រា៣ .-**

វាក្យសព្ទដែលប្រើនៅក្នុងអនុក្រឹត្យនេះ មានដូចខាងក្រោម៖

- **កសិផលក្នុងសហគមន៍** សំដៅដល់ផលិតផលក្នុងសហគមន៍ មានដូចជា អង្ករ ត្រី សាច់ ស៊ុត ទឹកដោះសត្វ បន្លែ ផ្លែឈើ គ្រាប់ធញ្ញជាតិ ចំណីអាហារដែលបញ្ចូលមីក្រូសារជាតិជាដើម ដែលមានប្រភពពីផលិតកម្មដំបូង សម្រាប់ផ្គត់ផ្គង់នៅតាមសាលារៀនសាធារណៈ។
- **សាលារៀនគោលដៅ** សំដៅដល់សាលារៀនសាធារណៈ ដែលត្រូវបានជ្រើសរើស និងកំណត់សម្រាប់ការអនុវត្តកម្មវិធី។

## ជំពូកទី២
## គោលការណ៍ និងយន្តការគ្រប់គ្រងកម្មវិធី

**មាត្រា៤ ..**

ក្រសួងអប់រំ យុវជន និងកីឡា ជាស្ថាប័នដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធី។

**មាត្រា៥ ..**

ត្រូវបានបង្កើតគណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធី។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ប្រព័ន្ធគ្រប់គ្រង ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព រាល់ឯកសារពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី ដើម្បីគ្រប់គ្រង និងអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

**មាត្រា៧ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំប្រតិបត្តិកម្មវិធី។

**មាត្រា៨ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវកំណត់អំពីហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ស្តង់ដារសំណង់ផ្ទះបាយ និងកន្លែងសិស្សទទួលទានអាហារ នៅតាមសាលារៀនគោលដៅ នៅក្នុងសៀវភៅណែនាំប្រតិបត្តិកម្មវិធី។

## ជំពូកទី៣
## ប្រាក់ឧបត្ថម្ភរបបអាហារ

**មាត្រា៩ ..**

ប្រាក់ឧបត្ថម្ភរបបអាហារសម្រាប់សិស្ស ប្រាក់ឧបត្ថម្ភចុងភៅ និងវិធីសាស្ត្រកំណត់ចំនួនសិស្សដែលត្រូវទទួលរបបអាហារនៅតាមវេនសិក្សានីមួយៗក្នុងសាលារៀនគោលដៅ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា។

ការកំណត់ចំនួនចុងភៅ និងលក្ខណវិនិច្ឆ័យនៃការជ្រើសរើសចុងភៅ ត្រូវចែងក្នុងសៀវភៅណែនាំប្រតិបត្តិកម្មវិធី។

## ជំពូកទី៤
## ថវិកាអនុវត្តកម្មវិធី

**មាត្រា១០ ..**

រាល់ចំណាយលើការអនុវត្តកម្មវិធី ត្រូវផ្តល់ហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាពីប្រភពស្របច្បាប់ផ្សេងទៀត។

នីតិវិធី និងយន្តការគ្រប់គ្រង និងអនុវត្តថវិការដ្ឋ សម្រាប់ដំណើរការកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១១ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវគ្រោងចំណាយថវិកាប្រតិបត្តិការប្រចាំឆ្នាំ ដោយរាប់បញ្ចូលទាំងការជួសជុលតូច ទិញសម្ភារៈផ្ទះបាយ និងសម្ភារៈអនាម័យតាមការចាំបាច់សម្រាប់ការអនុវត្តកម្មវិធី ដោយភ្ជាប់មកជាមួយនូវព័ត៌មានលម្អិត ដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច។

**មាត្រា១២ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសិក្សា និងលើកគម្រោងថវិកាប្រចាំឆ្នាំស្ដីពីគម្រោងសាងសង់ និង/ឬជួសជុលផ្ទះបាយ និង/ឬកន្លែងសិស្សទទួលទានអាហារ ដោយភ្ជាប់មកជាមួយនូវព័ត៌មានលម្អិតនៃគម្រោងឱ្យបានមុនដំណាច់ខែមីនានៃឆ្នាំនីមួយៗ ដើម្បីដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេចតាមលទ្ធភាពថវិកាប្រចាំឆ្នាំ ស្របតាមប្រតិទិនថវិកា។

## ជំពូកទី៥

## ករណីប្រធានសក្តិ

**មាត្រា១៣ ..**

ក្នុងករណីប្រធានសក្តិ ដូចជាករណីដែលប្រទេសជាតិទាំងមូល ឬផ្នែកណាមួយ ជួបវិបត្តិធ្ងន់ធ្ងរដែលមិនអាចអនុញ្ញាតឱ្យដំណើរការបង្រៀន និងរៀន តាមសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា អាចបង្វែរប្រាក់ឧបត្ថម្ភរបបអាហារសិស្ស និងប្រាក់ឧបត្ថម្ភចុងភៅ ដើម្បីទិញស្បៀងចែកជូនដល់សិស្សមកពីគ្រួសារមានបណ្ណសមធម៌ និងចុងភៅ យកទៅចម្អិនហូបនៅតាមផ្ទះរៀងៗខ្លួនដោយមានការឯកភាពពីប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៦

## ភារកិច្ចរបស់ក្រសួង ស្ថាប័នក្នុងការអនុវត្តកម្មវិធី

**មាត្រា១៤ ..**

ក្រុមប្រឹក្សាជាតិគាំពារសង្គម មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលកិច្ចសហការរវាងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធនឹងកម្មវិធី
- ផ្តល់ការតម្រង់ទិសផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តក្នុងការអនុវត្តកម្មវិធី
- ពិនិត្យ តាមដាន និងវាយតម្លៃផ្តល់យោបល់លើវឌ្ឍនភាពនៃការអនុវត្តកម្មវិធី
- ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- រៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាព និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជូនរាជរដ្ឋាភិបាល។

**មាត្រា១៥ ..**

ក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធី
- រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រង និងអនុវត្តកម្មវិធី
- រៀបចំបង្កើតប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន សម្រាប់គ្រប់គ្រងកម្មវិធី
- ពង្រឹងសមត្ថភាពដល់មន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអប់រំ ផ្សព្វផ្សាយអំពីកម្មវិធី
- រៀបចំផែនការសកម្មភាព និងគម្រោងថវិកា សម្រាប់អនុវត្តកម្មវិធី
- រៀបចំរបាយការណ៍ ស្ដីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធី ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម

- ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។

**មាត្រា១៦ ..**

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានភារកិច្ចដូចខាងក្រោម៖

- សហការក្នុងការផ្តល់ការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការជំរុញការដាំបន្លែនៅតាមសាលារៀនដើម្បីបង្កើនអាហារូបត្ថម្ភនៅកម្ពុជា
- សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**មាត្រា១៧ ..**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ ផ្តល់យោបល់ និងសម្រេចលើគម្រោងថវិកាសម្រាប់ការអនុវត្តកម្មវិធី
- វិភាជថវិកាសម្រាប់ការអនុវត្តកម្មវិធី
- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ហិរញ្ញវត្ថុ និងសមិទ្ធកម្មរបស់កម្មវិធី
- សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**មាត្រា១៨ ..**

ក្រសួងមហាផ្ទៃ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំ និងបំពេញបន្ថែមលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបំពេញតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការអនុវត្តកម្មវិធី
- សហការក្នុងការផ្តល់ការបណ្តុះបណ្តាលជូនដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ
- ពង្រឹងយន្តការដែលមានស្រាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការពិនិត្យ តាមដាន និងគាំទ្រការអនុវត្តកម្មវិធី
- សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**មាត្រា១៩ ..**

ក្រសួងសុខាភិបាល មានភារកិច្ចដូចខាងក្រោម៖

- សហការក្នុងការផ្តល់ការបណ្តុះបណ្តាល ស្តីពីរបបអាហារ វិធានអនាម័យ និងព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពអាហារូបត្ថម្ភរបស់កុមារ
- ត្រួតពិនិត្យ អង្កេត តាមដានអនាម័យ សុវត្ថិភាពចំណីអាហារ និងគ្រប់គ្រងការពុលចំណីអាហារ
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំឯកសារពាក់ព័ន្ធនឹងរបបអាហារ និងវិធានអនាម័យសុវត្ថិភាពស្បៀង និងម្ហូបអាហារ
- សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**មាត្រា២០ ..**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចដូចខាងក្រោម៖

- សហការក្នុងការរៀបចំថ្លៃទំនិញ និងចលនាឱ្យមានសកម្មភាពផលិតកម្មកសិកម្ម ប្រកបដោយគុណភាព និងសុវត្ថិភាពនៅតាមសាលារៀនគោលដៅ
- សហការក្នុងការលើកកម្ពស់គុណភាព សុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភ

- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការផ្តល់ការបណ្តុះបណ្តាលស្តីពីចំណេះដឹងផលិតកម្ម កសិកម្មប្រកបដោយសុវត្ថិភាព
- សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**មាត្រា២១ ..**

ក្រសួងផែនការ មានភារកិច្ចដូចខាងក្រោម៖

- ផ្តល់ទិន្នន័យអំពីតំបន់មានបញ្ហាអសន្តិសុខស្បៀង អត្រាភាពក្រីក្រ និងគ្រួសារក្រីក្រ ដោយប្រើប្រាស់វិធីសាស្ត្រគណនាតំបន់តូចៗ
- សហការក្នុងការផ្តល់ការបណ្តុះបណ្តាលស្តីពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិនៅក្នុងអាហារ
- សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**មាត្រា២២ ..**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានភារកិច្ចដូចខាងក្រោម៖

- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការផ្លាស់ប្តូរព័ត៌មានអ្នកទទួលផលពីមូលនិធិជាតិជំនួយសង្គម
- ចូលរួមជំរុញ និងលើកកម្ពស់ជីវភាពរស់នៅរបស់គ្រួសារមានបណ្ណសមធម៌ឱ្យបានទទួលផលពីកម្មវិធី
- សហការជាមួយក្រសួង ស្ថាប័ន ក្នុងការលើកកម្ពស់សកម្មភាពរកចំណូលរបស់គ្រួសារមានបណ្ណសមធម៌ តាមរយៈការបណ្តុះបណ្តាល ការផ្តល់ជំនួយឧបត្ថម្ភ និងការជំរុញការផលិតកសិផលសម្រាប់ផ្គត់ផ្គង់មកកម្មវិធី
- សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**មាត្រា២៣ ..**

ក្រសួងកិច្ចការនារី មានភារកិច្ចដូចខាងក្រោម៖

- សហការក្នុងការលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃអាហារូបត្ថម្ភដល់ស្ត្រី និងកុមារ និងការអប់រំ ផ្សព្វផ្សាយស្តីពី ការជ្រើសរើសស្បៀងអាហារដែលមានមីក្រូសារជាតិ ដោយផ្សារភ្ជាប់ជាមួយការអនុវត្តកម្មវិធី
- ចលនាដល់ការផលិត និងប្រើប្រាស់កសិផលក្នុងសហគមន៍ដល់ក្រុមគោលដៅជាស្ត្រី តាមរយៈកម្មវិធីសួនបន្លែគ្រួសារ និងការចែកចាយដែលមានតម្លៃសមស្របតាមទីផ្សារ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ តាមរយៈគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីកម្មវិធី
- គាំទ្របច្ចេកទេសក្នុងការបញ្ជ្រាបយេនឌ័រ ក្នុងក្របខណ្ឌពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**មាត្រា២៤ ..**

រដ្ឋបាលក្រុង ស្រុក មានភារកិច្ចដូចខាងក្រោម៖

- ប្រមូលផ្តុំ និងបូកសរុបរាល់សំណើសុំទាំងអស់របស់សាលារៀនគោលដៅពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី ជូនក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្ត

- គាំទ្រ និងកៀរគរធនធាន ថវិកា សម្ភារៈ ដែលជាវិភាគទានពីអ្នកពាក់ព័ន្ធ សម្រាប់ការអនុវត្តកម្មវិធី
- គាំទ្រ និងសហការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធី
- សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

## ជំពូកទី៧
## របាយការណ៍ និងការត្រួតពិនិត្យការអនុវត្តកម្មវិធី

**មាត្រា២៥ .-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធី ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម និងចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

របាយការណ៍ប្រចាំត្រីមាស ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ។ របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវផ្តល់របាយការណ៍ផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា២៦ .-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្តីពីការអនុវត្តកម្មវិធីដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ការអនុវត្តកម្មវិធីនេះ ត្រូវស្ថិតនៅក្រោមអធិការកិច្ច និងសវនកម្មអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៧ .-**

ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម មានសិទ្ធិចាត់តាំងមន្ត្រីជំនាញពាក់ព័ន្ធចុះពិនិត្យ និងសង្កេតជាក់ស្តែងដល់ទីកន្លែង អំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនេះ។

## ជំពូកទី៨
## ការដោះស្រាយវិវាទ ឬបណ្តឹង

**មាត្រា២៨ .-**

វិវាទ ឬបណ្តឹងដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី ត្រូវដោះស្រាយក្នុងកម្រិតក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងករណីមិនអាចដោះស្រាយបានក្នុងកម្រិតក្រសួងអប់រំ យុវជន និងកីឡា វិវាទ ឬបណ្តឹងនោះ អាចត្រូវបានប្តឹងទៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម មុននឹងប្តឹងទៅតុលាការ។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា២៩ .-**

ប្រកាសអន្តរក្រសួងលេខ០៩០ (ស្តន) សហវ.ប្រក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា៣០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៧រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា** ✓

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ